# របាយការណ៍ប្រចាំខែកុម្ភៈ ឆ្នាំ ២០១៨ របស់នាយកដ្ឋានអភិវឌ្ឍន៍ជនជាតិភាគតិច

**១.សេចក្តីផ្តើម**

ព្រះរាជាណាចក្រកម្ពុជាបាន និងកំពុងមានការអភិវឌ្ឍន៍លើគ្រប់វិស័យ ក្រោមការដឹកនាំរបស់រាជរដ្ឋាភិបាលកម្ពុជា ដោយបានដាក់ចេញនូវគោលនយោបាយ និងផែនការយុទ្ធសាស្ត្រនានាជាច្រើន ដើម្បីអភិវឌ្ឍន៍សេដ្ឋកិច្ចសង្គម សំដៅធ្វើឱ្យជីវភាពប្រជាពលរដ្ឋទូទាំងប្រទេសកាន់តែប្រសើរឡើង។ ក្នុងនោះរាជរដ្ឋាភិបាលបានយកចិត្តទុកដាក់ខ្ពស់ចំពោះបងប្អូនជនជាតិដើមភាគតិច តាមរយៈការរៀបចំនូវក្របខណ្ឌគោលនយោបាយ និងក្របខណ្ឌគតិយុត្តិនានា ដើម្បីអភិវឌ្ឍន៍សហគមន៍ជនជាតិដើមភាគតិច ក្នុងគោលបំណងរក្សានូវអត្តសញ្ញាណ ប្រពៃណី វប្បធម៌ របស់បងប្អូនជនជាតិដើមភាគតិច ដែលមាន ២៤ក្រុមជនជាតិ និងមានចំនួនជាង ១,៤% នៃចំនួនប្រជាជនសរុប ហើយកំពុងរស់នៅក្នុងខេត្តចំនួន ១៥ខេត្ត។

នាយកដ្ឋានអភិវឌ្ឍន៍ជនជាតិភាគតិច ត្រូវបានបង្កើតឡើងក្នុងឆ្នាំ ២០០១ មានការិយាល័យចំនួន០៤ និងមជ្ឈមណ្ឌលចំនួន០១÷ (១).ការិយាល័យកិច្ចការទូទៅ (២).ការិយាល័យផែនការ និងទំនាក់ទំនងសាធារណៈ (៣).ការិយាល័យស្រាវជ្រាវ និងអភិវឌ្ឍន៍ (៤).ការិយាល័យអប់រំ និងបណ្តុះបណ្តាល និង (៥).មជ្ឈមណ្ឌលព័ត៌មានជាតិ។

**២.ស្ថានភាពមន្ត្រីរាជការ**

- ចំនួនមន្ត្រីរាជការសរុប ៣២នាក់ ស្ត្រី ១៤នាក់
- ប្រធាននាយកដ្ឋាន ០១នាក់
- អនុប្រធាននាយកដ្ឋាន ០៥នាក់ ស្ត្រី ០១នាក់
- មន្ត្រីស្ថិតក្រៅក្របខ័ណ្ឌដើម ០១នាក់
- មន្ត្រីស្ថិតទំនេរគ្មានបៀវត្ស ០១នាក់
- មន្ត្រីជាប់កិច្ចសន្យា ០១នាក់
- មន្ត្រីរាជការសហការជាមួយដៃគូអភិវឌ្ឍន៍ និងគម្រោងនានា ០១នាក់។

**៣.សកម្មភាពទំនាក់ទំនងជាមួយអង្គការជាតិ-អន្តរជាតិ**

នាយកដ្ឋានកំពុងសហការណ៍ជាមួយដៃគូអង្គការជាតិ និងអន្តរជាតិមួយចំនួន ដែលកំពុងធ្វើការងារពាក់ព័ន្ធនឹងការងារអភិវឌ្ឍន៍ជនជាតិដើមភាគតិចនៅតាមសហគមន៍គោលដៅ ។ អង្គការទាំងនោះរួមមាន អង្គការ ILO DPA CED ICSO WCS GAA UNOHCHR CIYA CIPO OPKC GIZ HA និងពន្លកខ្មែរ ។

**៤.សកម្មភាពការងាររបស់នាយកដ្ឋាន**

សកម្មភាពនាយកដ្ឋានក្នុងខែកុម្ភៈ នេះ មានដូចខាងក្រោម÷

**ក. សកម្មភាពថ្នាក់ដឹកនាំ**

- ថ្ងៃទី ១៤-១៥/កុម្ភៈ/២០១៨ លោកប្រធានបានអញ្ជើញចូលរួម ចុះរៀបចំ និងពិនិត្យការងាមុនទស្សនកិច្ចសិក្សា នៅតំបន់ជនជាតិដើមភាគតិច ក្រោមអធិបតីភាព លោកជំទាវ ម៉ាត់ ម៉ារ៉ា ដោយសហការជាមួយអង្គការដៃគូ (CIPO) នៅខេត្តមណ្ឌលគីរី

- ថ្ងៃទី ១៧/កុម្ភៈ/២០១៨ លោកប្រធានបានអញ្ជើញចូលរួម ជាវាគ្មិនក្នុងការផ្សព្វផ្សាយជាសាធារណៈ ស្តីពី **វឌ្ឍនភាពនៃជនជាតិដើមភាគតិចនៅកម្ពុជា និងផែនការថែរក្សា និងអភិវឌ្ឍន៍ជនជាតិដើមភាគតិច** នៅក្នុងកិច្ចប្រជុំសមាជិកភាពប្រចាំត្រីមាសរបស់វេទិការនៃអង្គការមិនមែនរដ្ឋាភិបាល ស្តីពីកម្ពុជា នៅសាលប្រជុំនៃមជ្ឈមណ្ឌលព័ន្ធកិច្ចឯកភាពគ្រីស្ទបរិស័ទភ្នំពេញ រាជធានីភ្នំពេញ
- ថ្ងៃទី ០៩/កុម្ភៈ/២០១៨ លោកប្រធានបានអញ្ជើញចូលរួមប្រជុំស្តីពីការសរសេរបាយការណ៍សិទ្ធមនុស្សក្នុងវិស័យអភិវឌ្ឍន៍ជនបទ ក្រោមអធិបតីភាព **ឯកឧត្តម សាន វិសាល** អនុរដ្ឋលេខាធិការ និងជាប្រធានក្រុមការងារដឹកនាំការសរសេរបាយការណ៍ស្តីពីសិទ្ធិមនុស្សក្នុងវិស័យអភិវឌ្ឍន៍ជនបទ នៅសាលប្រជុំជាន់ទី៣ ទីស្តីការក្រសួង
- ថ្ងៃទី ០៧/កុម្ភៈ/២០១៨ លោកប្រធានបានអញ្ជើញចូលរួមកិច្ចប្រជុំរៀបចំគម្រោងកម្មវិធីវិនិយោគសាធារណៈ ៣ឆ្នាំរំកិល ឆ្នាំ ២០១៩-២០២១ របស់ក្រសួងអភិវឌ្ឍន៍ជនបទ នៅសាលប្រជុំជាន់ទី៣ ទីស្តីការក្រសួង
- នៅរសៀលថ្ងៃទី ០៦/កុម្ភៈ/២០១៨ លោកប្រធានបានអញ្ជើញចូលរួមប្រជុំពិភាក្សារៀបចំរបាយការណ៍សមិទ្ធផល និងការដាក់តាំងសមិទ្ធផលរបស់ក្រសួងអភិវឌ្ឍន៍ជនបទក្នុងរយៈពេល ២០ឆ្នាំ (១៩៩៨-២០១៧) ក្នុងទីតាំងវិមានអនុស្សាវរីយ៍នយោបាយឈ្នះឈ្នះ និងការបញ្ចប់សង្គ្រាមស៊ីវិលនៅកម្ពុជា បន្តលើកទី៣ ក្រោមអធិបតីភាព **ឯកឧត្តម ហួត សារឹម** ប្រធានគណៈកម្មការ នៅសាលប្រជុំជាន់ទី៣ ទីស្តីការក្រសួង
- ថ្ងៃទី ០៦/កុម្ភៈ/២០១៨ លោកប្រធានបានអញ្ជើញចូលរួមប្រជុំស្តីពីការអនុវត្តថវិកាកម្មវិធីប្រចាំខែមករា ឆ្នាំ ២០១៨ ក្រោមអធិបតីភាព **ឯកឧត្តម ហួត សារឹម** អនុរដ្ឋលេខាក្រសួងអភិវឌ្ឍន៍ជនបទ នៅសាលប្រជុំជាន់ទី៣ ទីស្តីការក្រសួង
- ថ្ងៃទី ០៥/កុម្ភៈ/២០១៨ លោកប្រធានបានអញ្ជើញចូលរួមអមដំណើរ **ឯកឧត្តមបណ្ឌិតរដ្ឋមន្ត្រី** អញ្ជើញចុះបេសកកម្ម ខេត្តត្បូងឃ្មុំ និងខេត្តកំពង់ចាម។

### ខ. ការងារកិច្ចការទូទៅ

នៅក្នុងខែកុម្ភៈ ឆ្នាំ ២០១៨ នេះ ការិយាល័យកិច្ចការទូទៅអនុវត្តការងារបានដូចតទៅ÷

- ទទួលលិខិតចូលបានចំនួន ១៧លិខិត
- ទទួលលិខិតចូលក្រៅក្រសួងបានចំនួន ០៤លិខិត
- កសាងលិខិតចេញបានចំនួន ២៥លិខិត។

### គ. ការងារអប់រំ និងបណ្តុះបណ្តាល

- ថ្ងៃទី ០៨/កុម្ភៈ/២០១៨ មន្ត្រី ០១រូប បានចូលរួមសិក្ខាសាលាផ្សព្វផ្សាយស្តីពីអាហារូបករណ៍ទៅសិក្សានៅប្រទេសអូស្ត្រាលី ក្រោមអធិបតីភាព លោកជំទាវ រដ្ឋមន្ត្រីក្រសួងកិច្ចការនារី និងលោកជំទាវឯកអគ្គរាជទូត នៅសណ្ឋាគារ រ៉ាស់ហ្វលឡឺរយ៉ាល់។

### ឃ. ការងារស្រាវជ្រាវ និងអភិវឌ្ឍន៍

- ធ្វើសំណើសុំទទួលស្គាល់សហគមន៍ជនជាតិដើមភាគតិច ចារ៉ាយ ភូមិ ក្លារ ភូមិ ម៉ុយ និងភូមិពែង ឃុំញ៉ាង ស្រុកអណ្តូងមាស ខេត្តរតនគិរី។

**ង. ការងារផែនការ និងទំនាក់ទំនងអន្តរជាតិ**

- បញ្ចូលទិន្នន័យសហគមន៍ជនជាតិដើមភាគតិចដែលបានចុះបញ្ជីកន្លងមកសម្រេចបាន១២៨សហគមន៍
- ធ្វើរបាយការណ៍រាល់កិច្ចប្រជុំជាមួយអង្គការដៃគូពាក់ព័ន្ធនានា
- រៀបចំឯកសារផែនការថវិការបស់នាយកដ្ឋាន
- លើកផែនការកិច្ចប្រជុំ សិក្ខាសាលាសម្រាប់ឆ្នាំ ២០១៨
- លើកផែនការសម្រាប់រៀបចំអបអរសាទរទិវាអន្តរជាតិជនជាតិដើមភាគតិចពិភពលោកលើកទី២៤ សម្រាប់ឆ្នាំ ២០១៨។

**ច. ការងារផ្សេងៗ**

- បានទទួលមន្ត្រីរាជការក្របខណ្ឌថ្មីចំនួន ០៥រូប ឲ្យចូលបម្រើការងារក្នុងនាយកដ្ឋានអភិវឌ្ឍន៍ជនជាតិភាគតិច
- ថ្ងៃទី ៣១/មករា/២០១៨ មន្ត្រី ០១រូប បានចូលរួមក្នុងពិធីបុណ្យមាឃបូជា នៅបរិវេណឧបដ្ឋានសាលាមុខព្រះមហាសក្យមុនីចេតិយ ភ្នំព្រះរាជទ្រព្យ(ឧត្តុង្គ) ក្នុងស្រុកពញាលឺ ខេត្តកណ្តាល ។

**៥.ទិសដៅបន្ត**

បន្តអនុវត្តតាមផែនការយុទ្ធសាស្ត្ររបស់នាយកដ្ឋានសម្រាប់ ឆ្នាំ២០១៨។

**ប្រធាននាយកដ្ឋាន**